22140566

International Baccalaureate®
Baccalauréat International
Bachillerato Internacional

**KHMER A: LITERATURE – HIGHER LEVEL – PAPER 2**
**KHMER A : LITTÉRATURE – NIVEAU SUPÉRIEUR – ÉPREUVE 2**
**KHMER A: LITERATURA – NIVEL SUPERIOR – PRUEBA 2**

Monday 12 May 2014 (afternoon)
Lundi 12 mai 2014 (après-midi)
Lunes 12 de mayo de 2014 (tarde)

2 hours / 2 heures / 2 horas

INSTRUCTIONS TO CANDIDATES

- Do not open this examination paper until instructed to do so.
- Answer one essay question only. You must base your answer on at least two of the Part 3 works you have studied and compare and contrast these works in response to the question. Answers which are not based on a discussion of at least two Part 3 works will not score high marks.
- You are not permitted to bring copies of the works you have studied into the examination room.
- The maximum mark for this examination paper is *[25 marks]*.

INSTRUCTIONS DESTINÉES AUX CANDIDATS

- N’ouvrez pas cette épreuve avant d’y être autorisé(e).
- Traitez un seul sujet de composition. En basant votre réponse sur au moins deux des œuvres de la troisième partie que vous avez étudiées, vous devez comparer et opposer ces œuvres dans le cadre du sujet. Les réponses qui ne sont pas basées sur au moins deux des œuvres de la troisième partie n’obtiendront pas une note élevée.
- Vous n’êtes pas autorisé(e) à apporter des exemplaires des œuvres que vous avez étudiées dans la salle d’examen.
- Le nombre maximum de points pour cette épreuve d’examen est *[25 points]*.

INSTRUCCIONES PARA LOS ALUMNOS

- No abra esta prueba hasta que se lo autoricen.
- Conteste una sola pregunta de redacción. Base su respuesta en al menos dos de las obras estudiadas de la Parte 3, comparándolas y contrastándolas en relación con la pregunta. Las respuestas que no se basen en al menos dos obras de la Parte 3 no recibirán una puntuación alta.
- No está permitido traer copias de las obras estudiadas a la sala de examen.
- La puntuación máxima para esta prueba de examen es *[25 puntos]*.


© International Baccalaureate Organization 2014

https://xtremepape.rs/

*ចូរឆ្លើយសំណួរតែងសេចក្ដីតែ**មួយ**គត់។ អ្នកត្រូវឆ្លើយដោយផ្អែកទៅលើស្នាដៃ**យ៉ាងហោចណាស់ចំនួនពីរ** ក្នុងចំណោមស្នាដៃដែលអ្នកបានសិក្សាក្នុងការងារផ្នែកទី៣ ហើយ**ចូរធ្វើការប្រៀបធៀបនិងពិភាក្សា**ស្នាដៃទាំងនេះអោយឆ្លើយតបទៅនឹងសំណួរតែងសេចក្ដីដែលអ្នកបានជ្រើសរើស។ ចម្លើយដែល**មិន**ផ្អែកលើស្នាដៃយ៉ាងហោចណាស់ចំនួនពីរ ក្នុងចំណោមស្នាដៃដែលអ្នកបានសិក្សាក្នុងការងារផ្នែកទី៣ នឹង**មិន**ទទួលបានពិន្ទុច្រើនទេ។*

**រឿងល្ខោន**

1. "ជានិច្ចជាកាល វីរបុរសនិងមនុស្សកំណាចគឺជាតួអង្គសំខាន់របស់រឿងល្ខោន"។ ចូរស្វែងរកការវិវត្តនិងសារៈសំខាន់របស់វីរបុរសនិងមនុស្សកំណាច នៅក្នុងរឿងល្ខោនយ៉ាងហោចណាស់ពីរដែលអ្នកបានសិក្សារួចហើយ។

2. ដោយយោងតាមរឿងល្ខោនយ៉ាងហោចណាស់ពីរដែលអ្នកបានសិក្សារួចហើយ ចូរធ្វើការពិភាក្សាទៅលើវិធីសាស្ត្រនៃការប្រើការលាក់កំបាំងដែលអ្នកនិពន្ធរឿងល្ខោនប្រើដើម្បីបង្កើតឱកាសដែលធ្វើឱ្យភ្ញាក់ផ្អើល។

3. ដោយយោងតាមស្នាដៃយ៉ាងហោចណាស់ពីរដែលអ្នកបានសិក្សារួចហើយ ចូរធ្វើការប្រៀបធៀបទៅលើវិធីសាស្ត្រដែលអ្នកនិពន្ធប្រើ ដើម្បីបង្កើតគោលគំនិតរបស់ស្នាដៃ នៅក្នុងឈុតដំបូងនៃស្នាដៃ។

**កំណាព្យ**

4. "កវីនិពន្ធគួរតែជាអ្វីដែលតាមរយៈវាអ្នកអាចប៉ះ ភ្លក់ ស្រង់ក្លិន ស្ដាប់ និងមានអារម្មណ៍"។ ដោយយោងតាមកំណាព្យយ៉ាងហោចណាស់ពីរដែលអ្នកបានសិក្សារួចហើយ ចូរស្វែងរកថាតើកវីនិពន្ធបានបង្កើតនូវបទពិសោធន៍ខាងវិញ្ញាណដល់អ្នកអានយ៉ាងដូចម្ដេចខ្លះនិងដល់កំរិតណា ?

5. "ឃ្លាចុងក្រោយបង្អស់របស់កំណាព្យគួរតែស្ថិតនៅជាមួយអ្នកជានិច្ច"។ តើកវីយ៉ាងហោចណាស់ពីររូបបានបង្កើតការបញ្ចប់ពោរពេញដោយអត្ថន័យយ៉ាងដូចម្ដេច ? ចូរធ្វើការពិភាក្សា។

6. តើកវីយ៉ាងហោចណាស់ពីររូបដែលអ្នកបានសិក្សារួចហើយប្រើប្រាស់ "ការប្រើនិមិត្តរូប" ដល់កំរិតណា ដើម្បីទាក់ទាញអារម្មណ៍អ្នកអាន ?



https://xtremepape.rs/

**អក្សរសិល្ប៍ពាក្យរាយៈ រឿងប្រឌិត**

7. “ការសរសេរតាមបែបបំផ្លើសអាចទាក់ទាញអារម្មណ៍អ្នកឬក៏អាចធ្វើឱ្យអ្នកលែងចង់អាន”។ ដោយយោងតាមសេចក្តីថ្លែងខាងលើ ចូរធ្វើការពិភាក្សាទៅលើការប្រើប្រាស់ការបំផ្លើសនៅក្នុងរឿងប្រឌិតជាពាក្យរាយយ៉ាងហោចណាស់ពីរដែលអ្នកបានសិក្សារួចហើយ។

8. ចូរស្វែងរកនូវវិធីសាស្ត្រនៃការប្រើភាសាដែលអ្នកនិពន្ធប្រើនៅក្នុងរឿងប្រឌិត ដើម្បីបង្កើតតួអង្គ ក្នុងរឿងប្រឌិតជាពាក្យរាយយ៉ាងហោចណាស់ពីរដែលអ្នកបានសិក្សារួចហើយ។

9. “អ្នកនិពន្ធផាត់ពណ៌គំនូរដោយប្រើពាក្យ”។ តើសេចក្តីថ្លែងនេះពិតដល់កំរិតណាចំពោះការពិពណ៌នាដែលបានប្រើនៅក្នុងរឿងប្រឌិតជាពាក្យរាយយ៉ាងហោចណាស់ពីរដែលអ្នកបានសិក្សារួចហើយ ?

**អក្សរសិល្ប៍ពាក្យរាយៈ រឿងពិត**

10. តើអ្នកនិពន្ធប្រើកាលអាកាសយ៉ាងដូចម្តេច ដើម្បីបង្ហាញបញ្ហាសង្គមនៅក្នុងរឿងពិតជាពាក្យរាយយ៉ាងហោចណាស់ពីរដែលអ្នកបានសិក្សារួចហើយ ?

11. ដោយយោងតាមរឿងពិតជាពាក្យរាយយ៉ាងហោចណាស់ពីរដែលអ្នកបានសិក្សារួចហើយ ចូរធ្វើការប្រៀបធៀបទៅលើវិធីសាស្ត្រនៃការប្រើការកំប្លុកកំប្លែងដែលអ្នកនិពន្ធទាំងពីររូបប្រើ ដើម្បីទាក់ទាញអារម្មណ៍អ្នកអាន។

12. តើពាក្យប្រៀបធៀប និងការប្រៀបធៀបអាចត្រូវបានប្រើយ៉ាងដូចម្តេចដើម្បីបង្កើតមូលន័យរឿង? ចូរធ្វើការពិភាក្សាដោយយោងតាមរឿងពិតជាពាក្យរាយយ៉ាងហោចណាស់ពីរដែលអ្នកបានសិក្សារួចហើយ។

---



https://xtremepape.rs/